Check against delivery

# សន្និសីទជាតិស្តីពីការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ

ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣

សណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ

សហការរៀបចំដោយក្រសួងយុត្តិធម៌ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ក្រោមកិច្ចឧបត្ថម្ភពី UNICEF និង ការិយាល័យ OHCHR នៅកម្ពុជា

*ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោកស្រី វ៉ាន់ហ៊ី លី តំណាង* OHCHR-Cambodia,

*ក្នុងនាមអង្គការ* UNICEF *និង* OHCHR-Cambodia

## ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរពរាប់អាន

ជាបឋម សូមគោរពឯកឧត្តមប៊ុន ហុន ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម គឹម សន្តិភាព អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង សូមថ្លែងអំណរគុណដល់ក្រសួងរបស់ឯកឧត្តម ដែលបានសហការរៀបចំអង្គសន្និសីទថ្ងៃនេះ ក្រោម កិច្ចឧបត្ថម្ភពីទីភ្នាក់ងារអង្គការសហប្រជាជាតិយើង។ ខ្ញុំធ្វើចំណាប់អារម្មណ៍ស្វាគមន៍នេះ ក្នុងនាមអង្គ ការ UNICEF និងការិយាល័យ OHCHR នៅកម្ពុជា។

ព្រឹកនេះ ខ្ញុំសូមស្វាគមន៍ដល់អ្នកចូលរួមទាំងអស់ក្នុងអង្គសន្និសីទដ៏សំខាន់នេះ។ នេះគឺជាលើក ទីមួយហើយដែលមន្ត្រីរដ្ឋាភិបាល ជាពិសេសក្រសួងយុត្តិធម៌(ក្នុងអាណត្តិថ្មីរបស់ខ្លួន) គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា ប្រធានតុលាការ ព្រះរាជអាជ្ញា មេធាវីការពារក្តីជនក្រីក្រ អង្គការផ្តល់ជំនួយ ផ្នែកច្បាប់ និងម្ចាស់ជំនួយ មកចូលរួមជាមួយគ្នាពិភាក្សាពីយុទ្ធសាស្ត្រដែលអាចមានដើម្បីធ្វើឲ្យកាន់តែ ប្រសើរដល់សេវាកម្មជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ និងជនដែលងាយរងគ្រោះបំផុត រួមមានកុមារ និង ស្ត្រីនៅកម្ពុជា។ ខ្ញុំដឹងថា លោក លោកស្រីបានអញ្ជើញមកពីគ្រប់ខេត្ត-រាជធានី ចូលរួមក្នុងសន្និសីទនេះ ហើយខ្ញុំសូមថ្លែងអំណរគុណដល់លោក-លោកស្រីដែលបានចំណាយពេលវេលា និងខិតខំចូលរួមក្នុង សន្និសីទនេះ ជាមួយយើងនៅថ្ងៃនេះ។

ខ្ញុំសូមចាប់ផ្តើមជាមួយនឹងរឿងយ៉ាងសាមញ្ញ និងផ្ទាល់ខ្លួនមួយ ដែលបង្ហាញពីសារសំខាន់នៃសេវាជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ។ កាលពីឆ្នាំមុន ខ្ញុំបានទៅទស្សនកិច្ចមណ្ឌលអប់រំកែប្រែ "ម"១ គឺជាពន្ធនាគារធំជាងគេនៅភ្នំពេញ។ ក្នុងដំណើរទស្សនកិច្ចនោះ ខ្ញុំបានជួបមនុស្សម្នាក់ ដែលតាមការមើលឃើញជាក់ស្តែងគឺជាកុមារ ដែលតាមពិតទៅ មិនត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារជាមួយមនុស្សពេញវ័យទេ។ ក្មេងនេះមើលទៅទំនងជាមិនដឹងអ្វីទាំងអស់ វាមកពីគ្រួសារដ៏ក្រីក្រមួយ។ វាមិនយល់ពីដំណើរការច្បាប់ទេ ហើយត្រូវបានឃុំខ្លួននៅម១ អស់ជាច្រើនខែចំពោះបទល្មើសតូចតាចមួយ។ វាមានបញ្ហាសុខភាពមួយចំនួន។ យើងអាចស្រមៃមើលថាតើក្មេងនេះមានការភ័យខ្លាចយ៉ាងណា ក្នុងកំឡុងពេលឃុំខ្លួននេះ ឬវាបានទ្រាំទ្រយ៉ាងណានៅក្នុងពន្ធនាគារមនុស្សពេញវ័យ ដែលមានសុទ្ធតែអ្នកទោសឧក្រិដ្ឋ។ មិនមានជំនួយពីមេធាវី ប្រហែលជាវាត្រូវនៅទីនោះ "ម១" ជាច្រើនខែទៀត ឬអាចដល់ឆ្នាំផងក៏មិនដឹង។ យើងបានស្វះស្វែងរកមេធាវីជំនួយផ្នែកច្បាប់ដល់ជនក្រីក្រម្នាក់ ដែលមានបំណងការពាររឿងក្តីនេះនៅតុលាការ។ ជាលទ្ធផល សវនាការបានប្រព្រឹត្តទៅដោយមានការការពារត្រឹមត្រូវ ហើយក្មេងនេះត្រូវបានដោះលែងភ្លាមបន្ទាប់មក។ ទោះបីជាខ្ញុំសប្បាយចិត្តនឹងលទ្ធផលនៃរឿងក្តីនេះក៏ដោយ ក៏មិនអាចឲ្យខ្ញុំមិនគិតដល់អ្នកទោសជាច្រើនផ្សេងទៀត ដែលគួរតែបានប្រយោជន៍ពីជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនេះ តែពួកគេមិនមានលទ្ធភាពអាចរកបាន។ ឧទាហរណ៍នេះ បង្ហាញថាហេតុអ្វីបានជាយើងចាត់ទុកសន្និសីទនេះមានសារសំខាន់ ដោយសារតែជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ គឺជាម៉ែត្រស្មើភាពគ្នាដ៏សំខាន់មួយនៃយុត្តិធម៌។ ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ដាក់អ្នកមាន និងអ្នកក្រដែលជាជនជាប់ចោទ ឲ្យមានមូលដ្ឋានស្មើភាពគ្នា ធ្វើឲ្យប្រសើរដល់ឱកាសរបស់ពួកគេ ទទួលបានការការពារស្មើគ្នាក្នុងទំហំពេញលេញមួយពីច្បាប់។ ដោយគ្មានសេវាកម្មជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ យុត្តិធម៌នៅកម្ពុជា គឺសំរាប់តែអ្នកមាន អ្នកមានអំណាច និងអ្នកដែលមានទំនាក់ទំនងល្អតែប៉ុណ្ណោះ។

មុននឹងចាប់ផ្តើមពិភាក្សាពីយុទ្ធសាស្ត្រធ្វើឲ្យប្រសើរដល់សេវាកម្មជំនួយផ្នែកច្បាប់ យើងត្រូវតែច្បាស់ទាំងអស់គ្នាអំពីទស្សនៈនៃការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ។ នៅពេលគេនិយាយពីជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនៅកម្ពុជា គឺគេតែងតែសំដៅដល់ការការពារតាមផ្លូវច្បាប់ តែនៅតុលាការប៉ុណ្ណោះ។ ថ្ងៃនេះ ខ្ញុំចង់ឲ្យអ្នកពន្លាតទស្សនៈនេះ ឲ្យបានទូលាយជាងនេះ ដោយមានរួមបញ្ចូលការផ្តល់ប្រឹក្សាយោបល់ពីផ្លូវច្បាប់ ជំនួយ/ការការពារតាមផ្លូវច្បាប់ដល់ជនត្រូវចោទ ឬជនចាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ហើយដែលក្រីក្រ ឬងាយរងគ្រោះដោយសារតែហេតុផលណាមួយ។ ជនរងគ្រោះ និងសាក្សី ក៏គួរទទួលបានសេវាកម្មជំនួយផ្នែកច្បាប់បែបនេះដែរ។ ជាសង្ខេប នៅគ្រប់ដំណាក់កាលនៃទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងប្រព័ន្ធយុត្តិធម៌តម្រូវឲ្យមានជំនួយផ្នែកច្បាប់។

តាមទស្សនៈវិស័យសិទ្ធិមនុស្ស ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រគឺជាសិទ្ធិមនុស្សជាមូលដ្ឋានមួយ វាគឺជាធាតុផ្សំមួយយ៉ាងសំខាន់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌត្រឹមត្រូវ និងមានប្រសិទ្ធភាពដោយឈរលើមូលដ្ឋាននីតិរដ្ឋ។ វាក៏មានសារៈ សំខាន់ដល់ការទទួលបានសិទ្ធិមនុស្សដទៃទៀត រួមទាំង សិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ផងដែរ ជាពិសេសចំពោះអ្នកក្រីក្របំផុត ដែលមិនលទ្ធភាពបង់ថ្លៃដល់សេវាកម្មជំនួយផ្នែកច្បាប់។ លើសពីនេះ ការទទួលបានសេវាកម្មយុត្តិធម៌កាន់តែកើនឡើង អាចជួយបង្ការពីការប្រព្រឹត្តមិនគប្បីនៅស្ថានីយ៍ប៉ូលីស ជួយសំរាលដល់ភាពចង្អៀតណែននៅពន្ធនាគារ និងជួយកាត់បន្ថយដល់ការផ្តន្ទាទោសមិនត្រឹមត្រូវ។ គ្មានមន្ទិលឡើយដែលថា ប្រព័ន្ធជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ដែលកាន់តែមានប្រសិទ្ធភាព នឹងបង្កើនការការពារកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ហើយក៏ជួយធានាថាកុមារត្រូវតែបានប្រព្រឹត្តលើជាកុមារ។

ក្នុងករណីនេះ ស្ថានភាពនៅកម្ពុជា មានការបារម្ភមែនទែន។ ខ្ញុំស្នើសុំដល់អ្នកចូលរួមទាំងអស់ពិចារណាតើអស់លោកពេញចិត្ត ចំពោះសេវាកម្មជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនៅកម្ពុជាមួយភាគធំត្រូវបានផ្តល់ឲ្យដោយមេធាវីអង្គការក្រៅរដ្ឋាភិបាលដែលទទួលមូលនីធិពីម្ចាស់ជំនួយបរទេស។ យើងអាចនិយាយថាវាជាការប្រពៃណាស់ដែលមានម្ចាស់ជំនួយជួយលើផ្នែកនេះ នៅក្នុងដំណាក់កាលណាមួយ តែយើងដឹងថាម្ចាស់ជំនួយភាគច្រើនបានកាត់បន្ថយការគាំទ្ររបស់ខ្លួនដល់អង្គការក្រៅរដ្ឋាភិបាលដែលផ្តល់សេវាកម្មជំនួយផ្នែកច្បាប់នេះ ហើយនិន្នាការនេះនឹងនៅតែបន្តទៅទៀត។ រាជរដ្ឋាភិបាលផ្តល់មូលនីធិមួយចំនួនដល់គណៈមេធាវីសំរាប់សេវាកម្មជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនេះ តែថវិកាដែលបានលៃសំរាប់សកម្មភាពនេះ ជាសរុបនៅមានការខ្វះខាតច្រើន។ មេធាវីការពារជនក្រីក្រមានចំនួនតិច ហើយកាន់តែថយទៅៗ។ កាលពីឆ្នាំ២០១០ មេធាវីការពារជនក្រីក្រនៅកម្ពុជា មានចំនួន ១១៩រូប។ តាមការស្រាវជ្រាវថ្មីៗនេះ ដោយការិយាល័យ OHCHR ចំនួននេះបានធ្លាក់ចុះមកត្រឹម៧៦រូបប៉ុណ្ណោះ ក្នុងរយៈពេល៣ឆ្នាំ។ អង្គការ UNICEF បានគាំទ្រគណៈមេធាវី ក្នុងការបោះពុម្ពបញ្ជីជាតិនៃឈ្មោះមេធាវីការពារជនក្រីក្រ ដែលបានផ្សព្វផ្សាយនៅក្នុងអង្គសន្និសីទនេះដែរ។ នៅតាមខេត្តភាគច្រើន មិនមានមេធាវីជំនួយផ្នែកច្បាប់សូម្បីតែម្នាក់។ ការទទួលបានជំនួយពីមេធាវីនៅតាមស្ថានីយ៍ប៉ូលីស មានកំរិតស្តួចស្តើងមែនទែន ជាពិសេសនៅតាមខេត្តដាច់ស្រយាល។ ការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនៅក្នុងប្រទេស មិនស្ថិតស្ថេរ និងមិនមានប្រសិទ្ធភាពទេ។ សំរាប់ប្រជាជនកម្ពុជាជាច្រើន សេវាកម្មយុត្តិធម៌គឺជាវត្ថុប្រណិតដែលពួកគេមិនមានលទ្ធភាពរកបាន។

ត្រូវតែចាត់វិធានការជាបន្ទាន់ ហើយខ្ញុំសង្ឃឹមថា សន្និសីទថ្ងៃនេះ នឹងនាំមកនូវអនុសាសន៍មួយចំនួន និងការប្តេជ្ញាចិត្តដែលនឹងនាំកម្ពុជា ឆ្ពោះទៅរកការបង្កើតប្រព័ន្ធជំនួយផ្នែកច្បាប់ថ្នាក់ជាតិមួយ ជាមួយនឹងទស្សនៈមួយច្បាស់លាស់ថា ត្រូវធានាយ៉ាងណាឲ្យសេវាកម្មជំនួយផ្នែកច្បាប់ ត្រូវបានផ្តល់ជូនតាមមធ្យោបាយមួយជាប្រព័ន្ធ និងសំរាប់ទាំងអស់គ្នាដែលត្រូវការសេវាកម្មនេះ។ មានការចាត់វិធានការ

មួយចំនួនក្នុងបណ្តាឆ្នាំកន្លងមក ហើយខ្ញុំសូមទាញនូវការចាប់អារម្មណ៍របស់អស់លោក ចំពោះឯកសារនានាដែលមាននៅក្នុងកាតាបដែលប្រគល់ជូន។ ឯកសារទី១គឺជាការស្ទង់មតិធ្វើដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងអង្គការ EWMI អំពីសេវាកម្មជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ កាលពីឆ្នាំ២០០៦។ ឯកសារទី២ គឺជាការសិក្សាស្រាវជ្រាវដោយគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា អំពីសេវាកម្មជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ កាលពីឆ្នាំ២០១០។ និងឯកសារទី៣ គឺជាឯកសារដែលរៀបចំដោយ DANIDA ដែលធ្វើការជាមួយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីឆ្នាំ២០១១។ ខ្ញុំសូមធ្វើការកត់សំគាល់ថា ការទទួលខុសត្រូវលើសេវាកម្មជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ឥលូវនេះបានផ្ទេរមកក្រសួងយុត្តិធម៌វិញ។ ឯកសារទាំងបីនេះ ផ្តល់ព័ត៌មានពិស្តារអំពីស្ថានភាពជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនៅកម្ពុជា ហើយយើងគួរចាំទុកក្នុងចិត្តនៅពេលយើងធ្វើការពិភាក្សាគ្នា។

កាលពីឆ្នាំកន្លងទៅ អង្គការសហប្រជាជាតិ បានយកចិត្តទុកដាក់កាន់តែខ្លាំងដល់បញ្ហាជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនេះ។ កាលពីខែធ្នូ ឆ្នាំមុន ដោយផ្អែកលើកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មហាសន្និបាតអង្គការសហប្រជាជាតិ នៅបូរីញូយ៉ក បានអនុម័តគោលការណ៍ និងគោលការណ៍ណែនាំសហប្រជាជាតិអំពីជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ការិយាល័យយើងខ្ញុំ បានបកប្រែគោលការណ៍ទាំងនេះជាភាសាខ្មែរ ហើយក៏មានចែកជូនដល់អ្នកចូលរួមទាំងអស់ដែរ។

គោលការណ៍ និងគោលការណ៍ណែនាំទាំងនេះ គូសបញ្ជាក់ឡើងវិញពីករណីយកិច្ច និងការទទួលខុសត្រូវដំបូងរបស់រដ្ឋ ក្នុងការផ្តល់សេវាកម្មជំនួយផ្នែកច្បាប់នេះ ហើយត្រូវលៃធនធានមនុស្ស និងហិរញ្ញវត្ថុចាំបាច់ដល់ប្រព័ន្ធជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនេះ។ គោលការណ៍ទាំងនេះសង្កត់ធ្ងន់ថាជនដែលត្រូវសង្ស័យពី ឬជាប់ចោទពីបទល្មើសព្រហ្មទណ្ឌណាមួយ មានសិទ្ធិទទួលបានសេវាកម្មជំនួយផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ។ កុមារគួរផ្តល់អាទិភាពក្នុងការទទួលបានជំនួយផ្នែកច្បាប់។ គោលការណ៍ និងគោលការណ៍ណែនាំសហប្រជាជាតិ ក៏គូសបញ្ជាក់ផងដែរពីសិទ្ធិត្រូវជូនដំណឹងអំពីជំនួយផ្នែកច្បាប់នេះ - នេះគឺជាសារៈសំខាន់ពិសេសនៅកម្ពុជា ដែលប្រជាជនភាគច្រើនមិនបានដឹង សូម្បីតែពីអត្ថិភាពនៃសេវាកម្មជំនួយផ្នែកច្បាប់នេះ ដែលធ្វើឲ្យគេបាត់បង់សិទ្ធិទទួលបានប្រយោជន៍ពីជំនួយបែបនេះ។ នៅក្នុងគោលការណ៍នេះ ក៏មានផ្នែកពិស្តារមួយអំពីវិធានការពិសេសសំរាប់កុមារ។ ដូចដែលអស់លោកឃើញ នៅពេលអានគោលការណ៍ និងគោលការណ៍ណែនាំសហប្រជាជាតិអំពីជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ គោលការណ៍ទាំងនេះ ផ្តល់នូវការណែនាំជាក់ស្តែង និងមានប្រយោជន៍ដល់រដ្ឋក្នុងការព្យាយាមបង្កើតប្រព័ន្ធជំនួយផ្នែកច្បាប់ជាតិមួយដែលស្ថិតស្ថេរ និងមានប្រសិទ្ធភាព។

កាលពីពេលថ្មីនេះ យន្តការនានានៃសិទ្ធិមនុស្សសហប្រជាជាតិ ក៏បានយកចិត្តទុកដាក់ដល់បញ្ហាជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនេះដែរ។ អ្នករាយការណ៍ពិសេសអំពីឯករាជ្យភាពចៅក្រម និងមេធាវី បានដាក់របាយការណ៍តាមប្រធានបទរបស់លោកស្រីជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអំពីបញ្ហាជំនួយផ្នែកច្បាប់ដល់ជនក្រីក្រនេះ។ យើងក៏មានចែកជូននូវរបាយការណ៍នេះផងដែរ ដោយបកប្រែជាភាសាខ្មែរនូវផ្នែកដែលពាក់ព័ន្ធបំផុត។ ស្របគ្នានេះដែរ កាលពីប៉ុន្មានសប្តាហ៍កន្លងទៅនេះ គណៈកម្មាធិការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ បានផ្តល់អនុសាសន៍ដល់កម្ពុជា "ឲ្យបង្កើតគំរោងជំនួយផ្នែកច្បាប់ដល់ជនក្រីក្រទូលំទូលាយមួយ ដើម្បីធានាឲ្យស្ត្រីគ្រប់រូបទទួលបានដោយប្រសិទ្ធភាពនូវសេវាកម្មសាលាក្តី និងតុលាការ" ស្របតាមគោលការណ៍ និងគោលការណ៍ណែនាំសហប្រជាជាតិអំពីជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ។ ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ គឺជាសេចក្តីបារម្ភស្នូលរបស់លោកតំណាងពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍របស់លោកអំពីវិស័យយុត្តិធម៌កាលពីប៉ុន្មានឆ្នាំមុន។

ខ្ញុំជឿជាក់ថា អ្នកចូលរួមថ្ងៃនេះ នឹងធ្វើការជាមួយគ្នាដោយជោគជ័យ ក្នុងការស្វែងរកដំណោះស្រាយ ដើម្បីធានាថាជំនួយផ្នែកច្បាប់នឹងក្លាយជាការពិតនៅកម្ពុជា។ ប្រទេសនានានៅក្នុងតំបន់ ដូចជាឥណ្ឌូនេស៊ី បានធ្វើដោយជោគជ័យ។ ប្រសិនបើយើងជឿជាក់ថា វាមិនត្រឹមតែអាចធ្វើបាននោះទេ តែថែមទាំងជាអាណត្តិបញ្ញានោះ ពេលនេះអាទិភាពនានារបស់ជាតិត្រូវបានកំណត់ជាថ្មី ហើយនៅពេលដែលការឆ្លើយតបរបស់សេវាកម្មរាជរដ្ឋាភិបាលចំពោះប្រជាជនត្រូវបានពិនិត្យឡើងវិញ នោះគ្មានហេតុផលណាមួយដែលថា កម្ពុជាមិនអាចធ្វើបានដូចគ្នានោះទេ។ ខ្ញុំជឿជាក់ថាប្រសិនបើសេវាកម្មទាំងអស់របស់រាជរដ្ឋាភិបាលចែករំលែកគ្នាពីទស្សនៈនេះ ការដោះលែងក្មេងប្រុសម្នាក់នោះ អាចជួយគាត់មិនឲ្យជាប់ពន្ធនាគារជាង២-៣ឆ្នាំ។ នេះប្រហែលជាការចាប់ផ្តើមជីវិតថ្មី។ ឯកឧត្តម លោកជំទាវ លោក លោកស្រី នេះគឺជាតួនាទីរបស់អស់លោកទាំងអស់គ្នា។ នេះមិនមែនជាការប្រយុទ្ធនឹងភាពមិនច្បាស់លាស់នៃបទបញ្ញត្តិច្បាប់នោះទេ តែជាការបង្ការនឹងអំពើអយុត្តិធម៌។ នេះជាការជួយសង្គ្រោះជីវិត។

ខ្ញុំសង្ឃឹមដោយស្មោះត្រង់ថា អស់លោកនឹងចងចាំថ្ងៃនេះ និងនៅលើវិថីដ៏វែងទៅមុខទៀត ក្នុងការកសាងប្រព័ន្ធជំនួយផ្នែកច្បាប់ដ៏រឹងមាំមួយ។ យើងទាំងអស់គ្នានៅទីនេះ គឺជាអ្នកកាន់កូនសោរ។

សូមជូនពរឲ្យមានកិច្ចពិភាក្សាប្រកបដោយផ្លែផ្កានៅថ្ងៃនេះ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។